# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះជាម្ចាស់បង្ហាញព្រះយេស៊ូដល់មនុស្សលោក
# ភ្នំពេញថ្មីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៩
# ឲ្យយើងធ្វើជាគ្រីស្តទូតដើម្បីប្រកាសដំណឹងល្អ

**អត្ថបទទី១៖ អេសាយ ៦០,១-៦**

យេរូសាឡឹមអើយ! ចូរក្រោកឡើង បញ្ចាំងពន្លឺ ដ្បិតពន្លឺរបស់អ្នកមកដល់ហើយ! សិរីរុងរឿងរបស់ព្រះអម្ចាស់ភ្លឺមកលើអ្នកដូចថ្ងៃរះ។ អស ៦០,១

**អត្ថបទទី២៖ អេភេសូ ៣,២-៣ក.៥-៦**

នៅជំនាន់ដើម មនុស្សម្នាពុំបានស្គាល់គម្រោងការនេះ ដូចព្រះជាម្ចាស់បានបង្ហាញឲ្យក្រុមគ្រីស្តទូត និងព្យាការីដ៏វិសុទ្ធរបស់ព្រះអង្គនាបច្ចុប្បន្នកាលស្គាល់ តាមរយៈព្រះវិញ្ញាណនោះឡើយ អភ ៣,៥

**ដំណឹងល្អ៖ ម៉ាថាយ ២,១-១២**

កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេសប្បាយចិត្តពន់ប្រមាណ។ មថ ២,១០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះជាម្ចាស់ បង្ហាញព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គដល់មនុស្សលោក។ នៅយប់ព្រះយេស៊ូប្រសូត មានអ្នកគង្វាល មានអ្នកភូមិ ដែលទៅថ្វាយបង្គំព្រះឱរសយេស៊ូ ប៉ុន្តែថ្ងៃនេះមានហោរាចារ្យដែលមកពីឆ្ងាយ។ ពួកគេជាអ្នកដែលមានចំណេះដឹង ជាអ្នកដែលស្រាវជ្រាវអំពីសេចក្តីពិត គេចង់ស្វែងយល់និងស្វែងរកអំពីសេចក្តីពិត ការស្វែងយល់របស់គេណែនាំឲ្យគេមើលឃើញផ្កាយមួយដែលភ្លឺរបៀបប្លែក ហើយគេសុខចិត្តធ្វើដំណើរដើម្បីដើរតាមផ្កាយនេះ។ ហោរាចារ្យ ជាមនុស្សដែលមានឋានៈ ជាមនុស្សដែលមានសមត្ថភាព គេបានយកតង្វាយមកថ្វាយព្រះឱរសយេស៊ូសុទ្ធតែជារបស់មានតម្លៃ។ ផ្កាយបាននាំគេឲ្យមកដល់ភូមិបេថ្លេហិម ឃើញមានឪពុកម្តាយនិងទារកដែលទើបតែប្រសូត ណែនាំឲ្យគេមានអំណរសប្បាយ ដោយសារការស្វែងរករបស់គេជោគជ័យហើយ។ សេចក្តីពិត ដែលគេរកឃើញប្លែកពីអ្វីដែលគេសង្ឃឹម នៅពេលគេស្វែងរកគេមិនទៅសួរអ្នកគង្វាល ឬប្រជាជន ឬម្ចាស់ផ្ទះសំណាក់ គឺគេទៅគាល់ស្តេចតែម្តង។ គេបន្តទៅរកសេចក្តីពិត ដែលជាព្រះយេស៊ូផ្ទាល់ដែលសព្វថ្ងៃ ដូចយើងបានស្តាប់ក្នុងអត្ថបទទីពីរ "**មនុស្សទាំងអស់មានសិទ្ធិទទួលមរតក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ មានសិទ្ធិទទួលព្រះពរតាមព្រះបន្ទូលសន្យា**" មនុស្សទាំងអស់នៅលើផែនដីនេះមានសិទ្ធិស្គាល់ព្រះយេស៊ូ មានសិទ្ធិរកឃើញពន្លឺដែលណែនាំឲ្យយើងយល់អំពីសេចក្តីពិត។ សម្រាប់យើងដែលជាជនជាតិខ្មែរ ពេលយើងស្តាប់អត្ថបទនេះ យើងត្រូវតែពោរពេញដោយអំណរសប្បាយ ដោយសារយើង

អង្គុយនៅទីនេះព្រោះយើងបានបំពេញសិទ្ធិរបស់យើង គឺស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទទួលព្រះពរពីព្រះជាម្ចាស់ ធ្វើជាព្រះសហគមន៍ជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងក៏មានសិទ្ធិទទួលមរតក គឺព្រះយេស៊ូផ្ទាល់ដែលគង់នៅជាមួយយើង។

សិទ្ធិណែនាំឲ្យយើងមានតួនាទីដោយយកចិត្តទុកដាក់ ដូច្នេះសិទ្ធិរបស់យើងណែនាំឲ្យយើងមានតួនាទីមួយយ៉ាងពិសេស គឺយើងធ្វើដូចម្តេចដើម្បីណែនាំឲ្យបងប្អូនឯទៀតៗអាចចូលនៅក្នុងសិទ្ធិនេះ។ មានន័យថាតួនាទីរបស់យើង គឺណែនាំឲ្យបងប្អូនមួយចំនួនអាចរកឃើញសេចក្តីពិត អាចដើរតាមផ្លូវនេះដែលណែនាំឲ្យគេជួបជាមួយយើងដែលជាគ្រីស្តបរិស័ទ ដែលស្វាគមន៍គេ ដែលលើកទឹកចិត្តគេ ដែលផ្តល់កម្លាំងឲ្យគេ ដែលណែនាំឲ្យគេមានគោលដៅយ៉ាងច្បាស់លាស់នៅក្នុងជីវិតរបស់គេ។ គឺយើងណែនាំឲ្យគេមានសេចក្តីសុខ និងសុភមង្គល វាមិនមកពីទ្រព្យសម្បត្តិមិនមកពីសម្ភារៈដែលយើងមាន គឺសុភមង្គលមកពីយើងជាគ្រួសារដែលសុខសាន្តដែលចេះស្រឡាញ់ ដែលចេះតស៊ូរួមគ្នា ដែលចេះគោរពគ្នាទៅវិញទៅមក ដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។

ថ្ងៃនេះយើងគោរពព្រះយេស៊ូ ដែលជាព្រះហឫទ័យសន្តោសរបស់ព្រះជាម្ចាស់ ដែលចាប់កំណើតជាមនុស្ស។ នៅក្នុងសម្ពន្ធមេត្រីចាស់ ប៉ុន្មានដងដែលព្រះជាម្ចាស់បានលើកលែងទោសឲ្យមនុស្សលោក ដូចជាអាដាំ អេវ៉ា កាអ៊ិន អាបិែល លោកម៉ូសេ... ប៉ុន្តែនៅពេលនេះក្នុងពេលព្រះយេស៊ូប្រសូតនេះយើងឃើញយ៉ាងជាក់ស្តែង នេះជាព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលយាងមកចាប់កំណើតជាមនុស្ស ដើម្បីឲ្យយើងទាំងអស់មានជីវិតដ៏បរិបូរណ៍។

នៅក្នុងបុណ្យព្រះយេស៊ូប្រសូតកន្លងមក យើងបានប្រមូលមនុស្សទាំងក្មេងទាំងចាស់ជាច្រើនតាមកន្លែងយើងនីមួយៗ ដែលមកជួបជុំគ្នាដើម្បីមើលព្រះកុមារយេស៊ូ ដែលយើងបានសម្តែង។ សម្រាប់ខ្ញុំក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតខ្ញុំបានជួបយ៉ាងតិច ១៥០០០នាក់ នៅកន្លែងផ្សេងៗដែលបានចូលរួម ដែលបានជួបជុំគ្នាដើម្បីមើលព្រះកុមារយេស៊ូដែលប្រសូតហើយ។ មានន័យថាព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលចាប់កំណើតជាមនុស្សដើម្បីណែនាំឲ្យយើងទទួលសេចក្តីសង្ឃឹមថ្មីនៅក្នុងជីវិតរបស់យើង។ រឿងនេះកើតឡើង ២០០០ឆ្នាំមុន រហូតដល់សព្វថ្ងៃនៅគ្រប់ទីកន្លែង យើងមានគ្រីស្តបរិស័ទដែលអង្គុយអធិដ្ឋានគោរពព្រះយេស៊ូដែលមានជីវិត មានមនុស្សផ្សេងៗដែលមកមើលដោយសារគេចង់ស្គាល់សេចក្តីដូចហោរាចារ្យដែរ។

នៅពេលហោរាចារ្យទៅដល់កន្លែងព្រះយេស៊ូប្រសូត គេពោរពេញដោយអំណរសប្បាយ "**កាលហោរាចារ្យទាំងនោះឃើញផ្កាយគេសប្បាយចិត្តពន់ប្រមាណ**"។ សម្រាប់យើងឲ្យយើងសប្បាយចិត្តដែរ ដោយសារយើងអង្គុយនៅក្បែរព្រះយេស៊ូ ដែលយាងមកដើម្បីឲ្យយើងមានជីវិត នឹងសេចក្តីសង្ឃឹម។ ឲ្យយើងណែនាំបងប្អូនឯទៀតៗ អាចចូលរួមនៅក្នុងអំណរសប្បាយនេះដែរ

ដោយសារគេអាចមើលឃើញតាមរយៈសក្ខីភាពនិងជីវិតរបស់យើង អំពីវត្តមានរបស់ព្រះយេស៊ូ ដែលណែនាំឲ្យមនុស្សលោកទទួលការសង្គ្រោះ។ ព្រះយេស៊ូមិនយាងមក ដើម្បីបង្កើតអង្គការមនុស្សធម៌មួយ ប៉ុន្តែព្រះយេស៊ូយាងមកដើម្បីបង្កើតព្រះសហគមន៍ ដែលណែនាំឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ។ គេទទួលជីវិតថ្មី ដោយសារព្រះយេស៊ូយាងមកដើម្បីរំដោះអ្វីៗទាំងអស់ដែលជាអំពើបាប ភាពងងឹត ការអស់សង្ឃឹមនៅក្នុងដួងចិត្តរបស់យើងដើម្បីរកឃើញពន្លឺ ដើម្បីមានកម្លាំងទៅមុខ ដោយដឹងថានៅថ្ងៃចុងក្រោយយើងមានជីវិតអស់កល្បជានិច្ច យើងមើលឃើញព្រះយេស៊ូផ្ទាល់។ យើងពោរពេញដោយអំណរសប្បាយ ដោយសារពេលយើងទទួលមរណភាពយើងអាចមើលឃើញព្រះយេស៊ូផ្ទាល់តាមសេចក្តីសង្ឃឹមរបស់យើង។

ហោរាចារ្យបានយកជ័រល្វីងទេសមកថ្វាយព្រះឱរសយេស៊ូ គឺដើម្បីរំលឹកនៅថ្ងៃចុងក្រោយព្រះយេស៊ូសោយទិវង្គត មាសដើម្បីរំលឹកព្រះយេស៊ូជាស្តេចនៃមនុស្សលោក និងគ្រឿងក្រអូបដើម្បីរំលឹកកូនង៉ែតនេះជាព្រះជាម្ចាស់។ ដូច្នេះនៅក្នុងតង្វាយពិសេស ដែលហោរាចារ្យបានថ្វាយគេមើលឃើញទាំងអស់ ឋានៈរបស់ព្រះជាម្ចាស់ដែលជាស្តេចនៃមនុស្សលោក ដែលជាព្រះជាម្ចាស់ផ្ទាល់បានចាប់កំណើតជាមនុស្ស ប៉ុន្តែចុងក្រោយត្រូវសោយទិវង្គត ដើម្បីណែនាំឲ្យយើងទាំងអស់ចូលរួមនៅក្នុងជីវិតថ្មី។ អត្តសញ្ញាជ្រមុជទឹក ដែលយើងទទួល គឺយើងរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ យើងមើលឃើញអាថិកំបាំងនៃជំនឿរបស់យើងយ៉ាងជាក់ស្តែង ដើម្បីយល់ថាព្រះយេស៊ូប្រសូត ព្រះយេស៊ូសោយទិវង្គត និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញជារឿងតែមួយ។

ចាប់ពីពេលនេះតទៅ ឲ្យយើងរៀបចំខ្លួនដើម្បីធ្វើជាសាសនាទូត ទេវទូត គ្រីស្តទូត ដែលប្រកាសដំណឹងល្អដ៏អស្ចារ្យនេះ កុំខ្លាចអីដោយសារព្រះយេស៊ូចាប់កំណើតជាមនុស្ស ដើម្បីណែនាំឲ្យមនុស្សទាំងអស់ពោរពេញដោយសេចក្តីសុខសាន្ត។ ក្នុងឆ្នាំ២០១៩នេះ ឲ្យយើងយកចិត្តទុកដាក់ធ្វើជាទេវទូតយ៉ាងពិសេស ដើម្បីច្រៀងកោតសរសើរលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ឲ្យមនុស្សយ៉ាងច្រើនពេលស្តាប់លឺសម្លេងយើង ពេលមើលឃើញពន្លឺនៅក្នុងស្នាមញញឹមរបស់យើង និងពេលទទួលសេចក្តីស្រឡាញ់ពីដួងចិត្តរបស់យើង អាចយល់ថាខ្ញុំមកដល់ហើយ គឺដល់កន្លែងដែលមានសេចក្តីពិត។ អាម៉ែន៕